**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាបើកអធិដ្ឋានពេញមួយយប់នៅព្រះសហគមន៍សន្តិម៉ារីញញឹម**
**ចំការទៀង ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០**

# ព្រះជាម្ចាស់ជ្រើសរើសយើង ដោយសារយើងគាប់ព្រះហឫទ័យរបស់ព្រះអង្គជានិច្ច

អត្ថបទទី១៖ កិច្ចការ ១៣,១៣-២៥

*យើងរកបានមនុស្សម្នាក់ជាទីគាប់ចិត្តយើងណាស់ គឺដាវីឌជាបុត្ររបស់យេសាយ* ដ្បិតដាវីឌនឹងបំពេញតាមបំណងទាំងប៉ុន្មានរបស់យើង”។ កក ១៣,២២

ដំណឹងល្អ៖ យ៉ូហាន ១៣,១៦-២០

អ្នកណាទទួលអ្នកដែលខ្ញុំនឹងចាត់ឲ្យទៅ ក៏ដូចជាទទួលខ្ញុំ។ យហ ១៣,២០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងអធិដ្ឋានសម្រាប់ការត្រាស់ហៅលើកទី៩២ ដែលយើងសូមព្រះជាម្ចាស់ប្រទាន លោកបូជាចារ្យ បងប្រុសបងស្រី អ្នកបម្រើព្រះសហគមន៍របស់យើង។ អត្ថបទទាំងពីរណែនាំឱ្យយើងចូលយ៉ាងជ្រៅនៅក្នុងរបៀបដែលព្រះជាម្ចាស់ត្រាស់ហៅយើង។ ថ្ងៃនេះ យើងបានបន្តជាមួយព្រះយេស៊ូ ដែលជាគ្រូគង្វាលដ៏សប្បុរស និងយើងមានព្រះនាងម៉ារីដែលបានទទួលដំណឹងពីទេវទូតកាព្រីអែល គឺព្រះជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារីឱ្យធ្វើជាមាតារបស់ព្រះអង្គ ដើម្បីឲ្យព្រះយេស៊ូប្រសូតជាព្រះបុត្រារបស់ព្រះអង្គ ទៅជាគ្រូគង្វាលដ៏សប្បុរស ដើម្បីណែនាំពិភពលោកឱ្យរកឃើញផ្លូវ រកឃើញជីវិត និងរកឃើញសេចក្តីពិត។

អត្ថបទទីមួយ លោកសិលាវាយតម្លៃអំពីរបៀបដែលព្រះយេស៊ូបានណែនាំយើង។ ប៉ុន្តែ មានសក្ខីភាពមួយអំពីព្រះបន្ទូលដ៏សំខាន់គឺ “**ព្រះអង្គប្រទានសាក្ខីភាពអំពីព្រះបាទដាវីឌនេះថា យើងរកបានមនុស្សម្នាក់ជាទីគាប់ចិត្តយើងគឺដាវីដ ជាបុត្ររបស់អេសាយ ដ្បិតដាវីឌនឹងបំពេញតាមបំណងទាំងប៉ុន្មានរបស់យើង**”។ ពេលព្រះជាម្ចាស់បានជ្រើសរើសលោកដាវីឌ ដែលជាមនុស្សក្មេងម្នាក់អត់ដែលមានអ្នកនឹកឃើញថាធ្វើជាស្តេច។ ប៉ុន្តែ សំខាន់បំផុតគឺយើងរកបានមនុស្សម្នាក់ដែលជាទីគាប់ចិត្តយើង យុវជនដាវីឌម្នាក់នេះបានបំពេញបំណងទាំងប៉ុន្មានរបស់យើង។ ព្រះនាងម៉ារីក៏ដូចគ្នា នៅពេលទេវទូតកាព្រីអែល បានប្រាប់ដំណឹងល្អដល់ព្រះនាងម៉ារីថា “**ព្រះជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារី**” ដោយសារព្រះជាម្ចាស់បានរើសព្រះនាងម៉ារីដែលជានារីម្នាក់គាប់ចិត្តរបស់ព្រះអង្គ ដោយភ្ជាប់នឹងបំណងរបស់ព្រះអង្គទាំងប៉ុន្មាន។

អត្ថបទគម្ពីរដែលយើងស្ដាប់ថ្ងៃនេះគឺ ព្រះយេស៊ូដែលកំពុងជប់លៀងចុងក្រោយជាមួយក្រុមសាវ័ក ព្រះយេស៊ូបានលាងជើងពួកគេអស់ហើយ នៅពេលនោះព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំស្គាល់អស់អ្នកដែលខ្ញុំបានជ្រើសរើស**"។ នៅពេលនោះព្រះយេស៊ូនៅជាមួយគ្រីស្ដទូត១២នាក់ យ៉ូដាសគាត់ចេញហើយ ដោយសារគាត់ក្បត់ព្រះយេស៊ូទៅនៅជាមួយភាពងងឹត។ ព្រះយេស៊ូនៅជាមួយគ្រីស្ដទូត១១នាក់ដែលព្រះអង្គបានជ្រើសរើស ដោយសារព្រះយេស៊ូដឹងថា ម្នាក់ៗដែលព្រះអង្គបានជ្រើសរើស ជាទីគាប់ចិត្តនឹងព្រះជាម្ចាស់ ម្នាក់ៗបំពេញតាមបំណងទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ នេះជាការត្រាស់ហៅ។ ខ្ញុំមិនទទួលការត្រាស់ហៅ ដោយសារខ្ញុំនឹកឃើញចង់ធ្វើជាបូជាចារ្យតែប៉ុនហ្នឹង ការត្រាស់ហៅរបស់ខ្ញុំតាមរយៈសាក្សីភាព។ យើងបានស្ដាប់និស្សិតទេវវិទ្យាល័យធ្វើសាក្សីភាព គេបានឃើញបូជាចារ្យម្នាក់ បានឃើញគ្រីស្ដបរិស័ទម្នាក់ បានឃើញបងស្រីម្នាក់ បានឃើញគ្រីស្ដបរិស័ទម្នាក់ ដែលជាទេវទូតកាព្រីអ៊ែលសម្រាប់ពួកគាត់។ ទេវទូតកាព្រីអ៊ែល ជាសញ្ញាសម្គាល់នៃព្រះសូរសៀងរបស់ព្រះជាម្ចាស់ដែលកំពុងជ្រើសរើស។

ជាព្រះជាម្ចាស់ដែលជ្រើសរើស ហើយព្រះអង្គមិនជ្រើសរើសទូទៅ ព្រះជាម្ចាស់បានជ្រើសរើសយុវជនហ្នឹងយុវនារីហ្នឹង ដែលមានឈ្មោះច្បាស់លាស់។ ដោយសារព្រះជាម្ចាស់ដឹងថា យុវជនហ្នឹងយុវនារីហ្នឹង គាប់ចិត្តនឹងព្រះអង្គ និងបានបំពេញតាមបំណងរបស់ព្រះអង្គទាំងអស់។ នៅពេលព្រះជាម្ចាស់ជ្រើសរើសហើយ ព្រះជាម្ចាស់មិនលះបង់ចោល ដោយសារប៉ុន្មានដងប៉ុន្មានសារយើងភ័យដែរ **តើធ្វើយ៉ាងម៉េចដើម្បីទៅមុខ?** ព្រះនាងម៉ារីក៏ភ័យដែរ ធ្វើយ៉ាងម៉េចដើម្បីទៅមុខ? ខ្ញុំជាមនុស្សម្នាក់ដែលអត់ទាន់រៀបការ ធ្វើយ៉ាងម៉េចដើម្បីមានផ្ទៃពោះបាន? ដាវីឌជាយុវជនម្នាក់ក៏ភ័យដែរ "**ខ្ញុំធ្វើយ៉ាងម៉ែចដើម្បីទៅជាព្រះមហាក្សត្រ? ខ្ញុំមានកម្លាំងពីណា? មានសមត្ថភាពពីណា?**" សមត្ថភាពមកពីព្រះជាម្ចាស់ផ្ទាល់ ដែលបានជ្រើសរើសយុវជនដាវីឌ បានជ្រើសរើសយុវនារីម៉ារី ដើម្បីទៅជាព្រះមហាក្សត្រដឹកនាំប្រជារាស្ត្រអ៊ីស្រាអ៊ែល ដើម្បីទៅជាមាតារបស់ព្រះជាម្ចាស់ ដោយមានផ្ទៃពោះប្រសូតព្រះយេស៊ូដែលជាព្រះបុត្រាផ្ទាល់។

មនុស្សយើងអត់មានសមត្ថភាព ដើម្បីផ្ញើជីវិតទៅលើព្រះជាម្ចាស់អស់មួយជីវិត អត់មានសមត្ថភាពបម្រើព្រះជាម្ចាស់អស់មួយជីវិត។ ប៉ុន្តែ នៅពេលយើងឆ្លើយ "**បាទ**" ដូចយុវជនដាវីឌ នៅពេលយើងឆ្លើយ ដូចព្រះនាងម៉ារី "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**" នៅពេលហ្នឹងយើងដឹងថាសមត្ថភាពយើងមាន ដោយសារព្រះជាម្ចាស់គង់នៅ ដោយសារព្រះជាម្ចាស់ធ្វើដំណើរជាមួយយើង។ "**ខ្ញុំសូមប្រាប់ឱ្យអ្នករាល់គ្នាឲ្យដឹងច្បាស់ថា...**" តើអ្នករាល់គ្នាជាអ្នកណា? គឺក្រុមគ្រីស្ដទូតទាំងអស់។ "**អ្នកណាទទួលអ្នកដែលខ្ញុំនឹងចាត់ឱ្យទៅ ក៏ដូចជាបានទទួលខ្ញុំដែរ**" ដូច្នេះ យុវជនយុវនារីកុំភ័យខ្លាច នៅពេលដែលព្រះជាម្ចាស់បានជ្រើស

រើស ឱ្យទៅជាបូជាចារ្យ បងប្រុសបងស្រី បងប្អូនគ្រីស្តបរិស័ទដូចជាបងប្អូនដែលមិនទាន់ជាគ្រីស្តបរិស័ទ ទទួលស្វាគមន៍យើង ដោយសារជាព្រះយេស៊ូផ្ទាល់ដែលបានចាត់យើងឱ្យទៅ។ នៅពេលគេទទួលយើង បីដូចជាគេបានទទួលព្រះយេស៊ូដែរ។

យប់នេះឱ្យយើងអធិដ្ឋាន ទោះបីយើងអត់មានឈ្មោះនៅក្នុងបញ្ជីឈ្មោះបព្វជិតបព្វជីតាដែលបានចែកម៉ោងអធិដ្ឋាន តែឱ្យយើងដឹងថានៅក្នុងចិត្តរបស់យើង យើងយកពេលកន្លះម៉ោង មួយម៉ោង ពីរម៉ោង មួយយប់ ដើម្បីអធិដ្ឋាន ដើម្បីស្តាប់ការជ្រើសរើសរបស់ព្រះជាម្ចាស់ ដោយដឹងថាប្រសិនបើព្រះអង្គដាក់គោលបំណងនៅក្នុងដួងចិត្តរបស់យើង សាកមើលទៅ!។ យើងមិនអាចធ្វើខុសទេ ដោយសារព្រះជាម្ចាស់ចាប់ដៃយើង ព្រះជាម្ចាស់ចាត់យើងឱ្យទៅ ព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច យើងបានស្តាប់យ៉ាងច្បាស់ហើយថា "**ព្រះជាម្ចាស់ជាព្រះដែលគង់នៅ និងដែលមានជីវិត ដើម្បីឲ្យយើងមានជីវិតអស់កល្បជានិច្ច**"។

សូមព្រះអង្គប្រទានពរដល់ព្រះសហគមន៍របស់យើងទាំងអស់ ដល់ក្រុមគ្រួសាររបស់យើង ដល់គ្រីស្តបរិស័ទម្នាក់ៗ ដល់យុវជនយុវនារីទាំងអស់ ដល់បព្វជិតបព្វជីតា ដល់បូជាចារ្យយើងទាំងអស់ ដើម្បីរួបរួមគ្នាបន្តធ្វើដំណើរជាមួយព្រះយេស៊ូដែលជាគង្វាលដ៏សប្បុរស ជាមួយព្រះនាងម៉ារីដែលជាព្រះមាតា ដែលជាមាតារបស់យើង និងជាអ្នកដែលបង្ហាញផ្លូវដើម្បីធ្វើដំណើរតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ពិតមែន ឱ្យព្រះអង្គជ្រើសរើសយើង ដោយសារយើងភ្ជាប់និងគាប់ព្រះហឫទ័យរបស់ព្រះអង្គជានិច្ច។ អាម៉ែន៕